នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
ចូល លេខ: ២០២ របកទ
ម៉ោង: ១៥.៣០ ថ្ងៃទី ១៤.០១.២០
បញ្ជូនទៅ:
អ្នកទទួល:

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០១ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តកែប និងខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សារៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តកែប និងខេត្តមណ្ឌលគិរី ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២.ឯកឧត្តម | **ឆិត ចន្ថា** | រដ្ឋលេខាធិការប្រចាំការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៣.ឯកឧត្តម | **ជូ ទិជិត្ត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤.ឯកឧត្តម | **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៥.ឯកឧត្តម | **កែន សត្ថា** | អភិបាលនៃគណៈអភិបាលខេត្តកែប | អនុប្រធាន |
| ៦.ឯកឧត្តម | **ស្វាយ សំអ៊ាង** | អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី | អនុប្រធាន |
| ៧.ឯកឧត្តម | **ឈិត សុខុន** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | | |
|---|---|---|---|
| ៨.ឯកឧត្តម | គុល ធីរក្ស | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩.ឯកឧត្តម | សារុន ឫទ្ធា | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១០.ឯកឧត្តម | នូ សុខត្ថិ | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១១.ឯកឧត្តម | សៅ សុភាព | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១២.ឯកឧត្តម | ជា បូរ៉ា | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៣.ឯកឧត្តម | ឃោច ចាន់ធួន | រដ្ឋលេខាធិការក្រសួងជំ និងថាមពល | សមាជិក |
| ១៤.ឯកឧត្តម | ចាន់ ចេស្តា | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៥.ឯកឧត្តម | ហាប់ អូម៉ារី | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៦.ឯកឧត្តម | ជា សួន | រដ្ឋលេខាធិការប្រចាំការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៧.ឯកឧត្តម | ឈាន សុភាព | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨.ឯកឧត្តម | ស៊ុខ តុនហាប់ | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៩.ឯកឧត្តម | ធី ផល្លី | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២០.ឯកឧត្តម | ជា ទុន្នី | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ២១.ឯកឧត្តម | នេត មុន្នី | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ២២.ឯកឧត្តម | ថោង រដ្ឋសក្តិ | អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងទេសចរណ៍ | សមាជិក |
| ២៣.ឯកឧត្តម | ឈោម សាម៉ុត | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាអគ្គលេខាធិការ គ.ជ.វ.ទ នៃក្រសួងទេសចរណ៍ | សមាជិក |

ប្រការ២._

គណៈកម្មការអន្តរក្រសួងនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

-រៀបចំផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងខេត្តកែប និងខេត្តមណ្ឌលគិរី ដើម្បីធានាបាននូវការអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព

-សិក្សារៀបចំបង្កើតឱ្យមានផលិតផលទេសចរណ៍ថ្មីៗក្នុងខេត្តកែប និងខេត្តមណ្ឌលគិរី សំដៅបង្កើនការទាក់ទាញភ្ញៀវទេសចរបន្ថែម និងពន្យារការស្នាក់នៅរបស់ភ្ញៀវទេសចរ

-ពិនិត្យ សិក្សា រៀបចំឱ្យមានជាព្រឹត្តិការណ៍ទេសចរណ៍ សិល្បៈកំសាន្តធំៗនៅពេលយប់ ទាំងបុរាណ និងទំនើប ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ដែលអាចសហការរៀបចំជាមួយវិស័យឯកជន នៅតាមទីតាំងគោលដៅទេសចរណ៍នានាក្នុងខេត្តទាំងពីរ

-ពិនិត្យ សិក្សា រៀបចំរមណីយដ្ឋានទេសចរណ៍ធម្មជាតិ ដែលមានសក្តានុពលផ្សេងទៀតក្នុងខេត្តទាំងពីរ

-ធ្វើរបាយការណ៍អំពីលទ្ធផល ឬរបាយការណ៍អំពីវឌ្ឍនភាពការងាររបស់ខ្លួនជូនរាជរដ្ឋាភិបាលជ្រាប និងសុំការណែនាំ យ៉ាងយូរបីខែម្តង

-បំពេញភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣._**

សមាជិកគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មការអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការងារ និងកិច្ចប្រជុំជំនួស។

**ប្រការ៤._**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ៥._**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាសេនាធិការ និងក្រុមការងារបច្ចេកទេសអន្តរក្រសួងមួយចំនួនតាមការចាំបាច់ ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៦._**

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៧._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៦ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ